

## តើនរណាជាបុគ្គលិករបស់ STARTTS?

បុគ្គលិក STARTTS គឺជាអ្នកវិជ្ជាជីវៈមានការបណ្ដុះបណ្ដាលដែលមកពីវប្បធម៌ផ្សេងៗគ្នាជាច្រើន ហើយមានឯកទេសក្នុងការជួយអ្នកដែលបានជួបប្រទះនឹងបញ្ហាដ៏លំបាកនៅអតីតកាល។

## តើមានអ្វីកើតឡើងបើអតិថិជនចូលចិត្តនិយាយភាសាក្រៅពីអង់គ្លេស?

បុគ្គលិក STARTTS និយាយភាសាជាច្រើន ដូចជាអារ៉ាប់ ដារី ហ្វាស៊ី ហាហ្សារ៉ាហ្គី និងតាមិល ហើយទាំងអស់នេះប្រើអ្នកវិជ្ជាជីវៈបកប្រែភាសា នៅពេលត្រូវការ។

## តើព័ត៌មានរបស់អតិថិជននឹងត្រូវរក្សាសម្ងាត់ឬទេ?

សេវាកម្មរបស់ STARTTS ត្រូវបានលាក់ការសម្ងាត់។ STARTTS នឹងចែកចាយព័ត៌មានអំពីអតិថិជនណាមួយ បើគេផ្ដល់ការអនុញ្ញាតឲ្យយើង ហើយដើម្បីជួយអតិថិជនតែប៉ុណ្ណោះ។ ប៉ុន្តែ បើគេប្រាប់យើងថាគេប្រហែលជាបង្កគ្រោះថ្នាក់ដល់ខ្លួនគេ ឬជនដទៃទៀតប្រហែលជាមានគ្រោះថ្នាក់ នោះ STARTTS នឹងត្រូវការចាប់យកវិធានការដើម្បីការពារអតិថិជននេះ និងអ្នកដទៃ។

## អំពី STARTTS

STARTTS គឺជាអង្គការឯកទេសមិនយកប្រាក់ចំណេញមួយ ដែលបង្កើតឡើងកាលពីឆ្នាំ 1988។ អង្គការនេះផ្ដល់ការព្យាបាលនិងជំនួយផ្លូវចិត្ត ព្រមទាំងអន្តរាគមន៍សហគមន៍ដែលពាក់ព័ន្ធនឹងវប្បធម៌ ដើម្បីជួយបុគ្គលនិងសហគមន៍ទាំងឡាយដើម្បីផ្សះស្នាមរបួសនៃទារុណកម្មនិងបទពិសោធន៍ដ៏តក់ស្លុតនៃជនភៀសខ្លួន ហើយកសាងឡើងវិញនូវការរស់នៅរបស់គេនៅក្នុងប្រទេសអូស្ត្រាលី។ STARTTS ក៏ជំរុញឲ្យមានបរិស្ថានរើបរើឡើងវិញដ៏វិជ្ជមានផងដែរ តាមរយៈការផ្ដល់ការបណ្ដុះបណ្ដាលដល់សេវាកម្ម ការងារតស៊ូមតិនិងគោលការណ៍។

**www.startts.org.au**

## ទាក់ទងយើង

**ការិយាល័យកណ្ដាល CARRAMAR**
152-168 The Horsley Drive
Carramar NSW 2163
(02) 9646 6700

**ទីកន្លែងការិយាល័យផ្សេងទៀត**

| | | |
|---|---|---|
| Albury | Armidale | Auburn |
| Blacktown | Coffs Harbour | Fairfield |
| Liverpool | Newcastle | Wagga Wagga |
| Wollongong | | |

ចូលទៅកាន់ **www.startts.org.au/contact/** សម្រាប់ទទួលព័ត៌មានអំពីទីកន្លែងការិយាល័យ។

STARTTS ក៏ផ្ដល់ការពិគ្រោះយោបល់និងប្រភេទសេវាកម្មឯទៀតផងដែរ នៅតាមទីកន្លែងផ្សេងទៀតនៅក្នុងក្រុង Sydney និងពាសពេញរដ្ឋ NSW ដូចជា Blacktown, Parramatta, Dee Why, Lakemba, Penrith, Campbelltown, Rockdale, Tamworth, Griffith និង Albury។ ទីកន្លែងទាំងនេះផ្លាស់ប្ដូរដោយយោងទៅតាមសេចក្ដីត្រូវការនៃអតិថិជនរបស់យើង។ សូមទាក់ទង STARTTS ដើម្បីទទួលព័ត៌មានបន្ថែម។

Images: © Pixabay/sharonang | © STARTTS/Philip Raymond & David M Smith

Khmer

ព័ត៌មានសម្រាប់

# អតិថិជន



**សេវាកម្ម NSW សម្រាប់ការព្យាបាលនិងកាយនីតិសម្បទានៃជនរងគ្រោះដោយសារទារុណកម្មនិងការតក់ស្លុត (STARTTS)**

## តើ STARTTS សម្រាប់អ្នកណាខ្លះ?

STARTTS ធ្វើការជាមួយអ្នកដែលបានជួបប្រទះនឹងការធ្វើទុក្ខបុកម្នេញ សង្គ្រាម អំពើហិង្សា និងការរំលោភសិទ្ធិ មនុស្ស មុនពេលចូលមកដល់ប្រទេសអូស្ត្រាលី ហើយកំពុងមានការលំបាកដែលជាលទ្ធផល។ STARTTS អាចជួយបណ្តាជនទាំងឡាយ ដោយមិនគិតអំពីពេលឬរបៀបដែលគេបានមកដល់ប្រទេសអូស្ត្រាលីឡើយ។

## ហេតុអ្វីបានជាបុគ្គលណាមួយប្រហែលជាត្រូវការជំនួយពី STARTTS?

ការដោះស្រាយនឹងការរស់នៅក្នុងប្រទេសថ្មីមួយ នៅក្នុងពេលដោះស្រាយនឹងការចងចាំនូវអតីតកាលគួរឲ្យខ្លាច ជួនកាលអាចមានភាពខ្លាំងលើសលុប ដោយធ្វើឲ្យគេមានអារម្មណ៍ព្រួយបារម្ភនិងច្រឡូកច្រឡំ។ វាអាចមានផលប៉ះពាល់លើសុខភាពនិងការរស់នៅប្រចាំថ្ងៃរបស់គេ។

ប្រតិកម្មទូទៅខ្លះមានរួមទាំង៖

- ការលំបាកក្នុងការរៀនភាសាអង់គ្លេស
- បញ្ហាដំណេកនិងយល់សប្តិអាក្រក់
- ការចងចាំរឿងអតីតកាលដែលនឹងនៅជិតជាប់ជានិច្ច
- ឈឺក្បាលនិងឈឺរាងកាយ
- ការឆាប់ខឹងឬឆាប់ភ័យខ្លាច
- ការមានអារម្មណ៍អស់សង្ឃឹមឬមិនអាចធ្វើអ្វីបានដោយខ្លួនឯង
- ការយល់ថា មិនគ្រប់គ្រងការរស់នៅរបស់ខ្លួនតទៅទៀត
- ភាពតានតឹងក្នុងរង្វង់គ្រួសារ
- ការយល់ថាមានការលំបាកក្នុងការទុកចិត្តអ្នកដទៃឬមានមិត្តភក្តិថ្មី និងមានអារម្មណ៍តែលតោល

## តើ STARTTS នឹងអាចជួយបានឬទេ?

STARTTS មានឯកទេសក្នុងការជួយគាំទ្រអ្នកដែលបានជួបប្រទះនឹងស្ថានការណ៍លំបាកនៅអតីតកាល ដើម្បីឲ្យជាសះស្បើយ និងឲ្យជីវិតមានភាពកាន់តែប្រសើរឡើង។ នៅពេលដែលខ្លួនយើងមានអារម្មណ៍ថា យើងមានសម្ពាធកាន់តែតិច ហើយមានការគ្រប់គ្រងរឹតតែខ្លាំង នោះវារឹតតែងាយស្រួលក្នុងការសិក្សាភាសាអង់គ្លេស មានការងារធ្វើ ត្រូវរ៉ូវគ្នាជាមួយគ្រួសារ និងមានមិត្តភក្តិថ្មី។



## តើ STARTTS អាចជួយបានតាមវិធីណា?

អ្នកពិគ្រោះយោបល់ម្នាក់របស់ STARTTS អាចពិភាក្សាជាមួយបុគ្គលនោះអំពីការបារម្ភនិងទុក្ខព្រួយរបស់គេ។ បុគ្គលនោះអាចនិយាយអំពីការបារម្ភឬការលំបាកណាមួយដែលគេអាចប្រឈមមុខ ភ្ជាប់គេទៅកាន់អ្នកឬអង្គការដែលអាចជួយដោះស្រាយបញ្ហា ហើយជួយគេឲ្យយល់អំពីរបៀបដែលអូស្ត្រាលីបំពេញការងារ។

## បើនរណាមួយមានបំណងចូលជាសមាជិកនៃក្រុមមួយ

STARTTS មានក្រុមច្រើនប្រភេទជាភាសាផ្សេងៗគ្នា សម្រាប់អ្នកដែលចូលចិត្តចង់បានជំនួយរបស់ក្រុម ជាជាងការផ្តល់ឱវាទរៀងខ្លួន។ ក្រុមទាំងឡាយធ្វើដំណើរការនៅពេលដែល STARTTS មានអ្នកចាប់អារម្មណ៍គ្រប់គ្រាន់តែប៉ុណ្ណោះ។ ក្រុមទាំងឡាយមានរួមទាំងគ្រួសារនៅក្នុងអន្តរវប្បធម៌ ការពិគ្រោះយោបល់ជាក្រុម ក្រុមជំនួយសង្គម ក្រុមកីឡា ក្រុមសិល្បៈ និងជំរំយុវជន។

## ការបញ្ជូនទៅកាន់ STARTTS

STARTTS ទទួលយកការបញ្ជូនពីប្រភពទាំងអស់ ដោយមានរួមទាំងការបញ្ជូនដោយខ្លួនឯងផងដែរ។

**ដើម្បីធ្វើការបញ្ជូនទៅកាន់ STARTTS៖**

- **ទូរស័ព្ទទៅលេខ (02) 9646 6800**
- **អ៊ីមែលទៅ STTS-IntakeGeneral@health.nsw.gov.au**
  (ទម្រង់បំពេញបែបបទមាននៅតាមវិបសៃ STARTTS)

## តើរយៈពេលប៉ុន្មានដែលអតិថិជនត្រូវតែរង់ចាំ?

STARTTS គ្មានបញ្ជីរង់ចាំទេ ដូច្នេះអតិថិជននឹងប្រហែលជាត្រូវការរង់ចាំប្រហែល 2-4 អាទិត្យ រហូតទាល់តែអ្នកពិគ្រោះយោបល់ម្នាក់ទូរស័ព្ទទៅគាត់ដើម្បីធ្វើការណាត់ជួប។

## តើអតិថិជនអាចទៅជួបដោយគ្មានការណាត់ជួបឬទេ?

អតិថិជនអាចទៅជួបដើម្បីបញ្ជូនខ្លួនឯងទៅកាន់ STARTTS ប៉ុន្តែដើម្បីចូលរួមការប្រជុំពិគ្រោះយោបល់ អតិថិជននោះត្រូវតែមានការណាត់ជួប។

## តើ STARTTS អស់ថ្លៃប៉ុន្មាន?

សេវាកម្ម STARTTS ទាំងអស់ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់អតិថិជនដែលយើងជួយ។

## តើអតិថិជនត្រូវមានអាយុប៉ុន្មាន?

STARTTS ជួយអតិថិជនគ្រប់អាយុទាំងអស់ ចាប់តាំងពីក្មេងតូចរហូតដល់វ័យចំណាស់។ បើអតិថិជនមានអាយុ 16 ឆ្នាំឬតិចជាងនេះ STARTTS នឹងត្រូវការការអនុញ្ញាតពីមាតាឬបិតា ឬអ្នកអាណាព្យាបាលរបស់អតិថិជននោះ។

## តើអតិថិជនត្រូវធ្វើដំណើរទៅទីណា?

STARTTS បម្រើអតិថិជននៅក្នុងក្រុង Sydney និងនៅតាមតំបន់ជនបទនៃរដ្ឋ NSW នៅតាម៖

- ការិយាល័យរបស់ STARTTS
- ទីកន្លែងផ្សេងទៀតរបស់ STARTTS ដូចជានៅតាមមណ្ឌលសុខភាពសហគមន៍ និង TAFE
- សាលារៀន (សម្រាប់សិស្សនៅសាលារៀននោះ)